**<u>សំណួរ</u>**

**អ្វីទៅជាខរក្សាសិទ្ធិមិនអនុវត្ត**

**<u>ចម្លើយ</u>**

ច្បាប់ មានច្បាប់ជាតិ និងអន្តរជាតិ។ ច្បាប់ទាំងពីរនេះ កើតមុនឬក្រោយគ្នា។ ច្បាប់ជាតិ អនុម័តមុនសន្ធិសញ្ញាដែលរដ្ឋបានក្លាយជាភាគី ហើយមានបទប្បញ្ញត្តិខ្លះ ផ្ទុយនឹងខ្លឹមសារនៃសន្ធិសញ្ញានោះ។ ដើម្បីឲ្យស្រប រដ្ឋ អាចធ្វើវិសោធនកម្ម ច្បាប់ក្នុងស្រុកឲ្យស្របជាមុន មុនផ្តល់សច្ចាប័នដល់សន្ធិសញ្ញា ដើម្បីបង្កាការអនុវត្តតាមកាតព្វកិច្ចអន្តរជាតិមិនបាន នាំឲ្យមានការចោទថាបំពានកាតព្វកិច្ច។ វិធានច្បាប់អន្តរជាតិបានចែង មិនឲ្យលើកយកច្បាប់ជាតិមកសំអាងដោះសារ ចំពោះការខកខានមិនបានបំពេញតាមកាតព្វកិច្ច (មាត្រា ២៧ នៃអនុសញ្ញា ឆ្នាំ ១៩៦៩ ស្តីពី ច្បាប់សន្ធិសញ្ញា)។ ជាដំណោះស្រាយ ច្បាប់អន្តរជាតិ បានអនុញ្ញាតឲ្យមាន ការចុះខរក្សាសិទ្ធិមិនអនុវត្ត។ តើអ្វីទៅជាខករក្សាសិទ្ធិមិនអនុវត្ត?

វាជាសេចក្តីថ្លែងការណ៍ឯកតោភាគីរបស់រដ្ឋ ក្នុងន័យកែសម្រួល ឬធ្វើប៉ះវិសាលភាពនៃកាតព្វកិច្ចក្នុងបទប្បញ្ញត្តិដែលពាក់ព័ន្ធ។[1] ក្នុងន័យនេះ គ្រាន់តែជាសេចក្តីថ្លែងការណ៍ (declaration) បង្ហាញពីជំហរ មិនមានបញ្ហាផ្លូវច្បាប់ទេ ពីព្រោះវាមិនកែប្រែវិសាលភាពនៃកាតព្វកិច្ច។ ឧទាហរណ៍ កម្ពុជា បានធ្វើសេចក្តីថ្លែងការណ៍ នៅពេលចូលជាភាគី នៃពិធីសារស្តីពី កុមារក្នុងជម្លោះប្រដាប់អាវុធ ថា តាមច្បាប់កម្ពុជា កុមារជាបុគ្គល ដែលមានអាយុក្រោម ១៨ ឆ្នាំ។[2]

ជាទូទៅ ប្រសិនសន្ធិសញ្ញា ឬកិច្ចព្រមព្រៀង មិនហាមឃាត់ទេ រដ្ឋអាចចុះខរក្សាសិទ្ធិមិនអនុវត្ត បទប្បញ្ញត្តិណាមួយនៃសន្ធិសញ្ញា ដែលខ្លួនចង់ចូលជាភាគី កុំឲ្យតែខ្លឹមសារនៃខរក្សាសិទ្ធិ ខុសពីគោលបំណងនៃកិច្ចព្រមព្រៀងនោះ។ ទោះបីជាយ៉ាងនេះក្តី សន្ធិសញ្ញាខ្លះ ចែងឲ្យចុះខរក្សាសិទ្ធិជាក់លាក់លើបទប្បញ្ញត្តិណាមួយ[3] ឬ នៅពេលតែផ្តល់សច្ចាប័ន។[4] ជាទូទៅ រដ្ឋចុះខរក្សាសិទ្ធិនាពេល ចុះហត្ថលេខា ឬផ្តល់សច្ចាប័ន។

ស្រដៀងគ្នានេះ រដ្ឋអាចដកយកមកវិញនូវខរក្សាសិទ្ធិមិនអនុវត្ត។ ឧទាហរណ៍ នៅពេលបទប្បញ្ញត្តិច្បាប់ ដែលផ្ទុយនឹងខ្លឹមសារនៃសន្ធិសញ្ញាលែងផ្ទុយ (ដោយសារ សភា បានធ្វើវិសោធនកម្មរួចហើយ)។ រដ្ឋដទៃ អាចធ្វើការជំទាស់ ដល់ខរក្សាសិទ្ធិចុះដោយរដ្ឋផ្សេង ហើយក៏អាចដកការជំទាស់វិញនាពេលណាក៏បាន។

---

[1] Article 2 of Vienna Convention on Law of Treaties 1969; USA reservation to Article 7 of ICCPR (3) That the United States considers itself bound by Article 7 to the extent that "cruel, inhuman or degrading treatment or punishment" means the cruel and unusual treatment or punishment prohibited by the Fifth, Eighth and/or Fourteenth Amendments to the Constitution of the United States.

[2] Declaration of Cambodia, https://treaties.un.org/Pages/ViewDetails.aspx?src=IND&mtdsg_no=IV-11-b&chapter=4&clang=_en#EndDec

[3] Article 57, European Convention for the Protection of Human Rights and Fundamental Freedoms, 1950.

[4] See generally, UN Treaty Handbook, 2012.

រដ្ឋខ្លះ បញ្ជូនខ្លឹមសារនៃការចុះខរក្សាសិទ្ធិ ភ្ជាប់ទៅជាមួយនឹងអត្ថបទសន្ធិសញ្ញាជាភាសាជាតិ ដើម្បីឲ្យសភា ពិនិត្យ ពិចារណាផងដែរ ជាមួយនឹងអត្ថបទសន្ធិសញ្ញា។ ផ្ទុយទៅវិញ រដ្ឋខ្លះ ទុកការងារនៃការចុះខរក្សាសិទ្ធិ ជាកិច្ចការងាររបស់រដ្ឋាភិបាល និងមិនចាំបាច់ឆ្លងសភាទេ។

ការចុះខរក្សាសិទ្ធិ មានប្រយោជន៍ ដើម្បីការពារប្រយោជន៍របស់ជាតិ និង រួចផុតពីការចោទប្រកាន់នូវការបំពានកាតព្វកិច្ច ដោយសារកាតព្វកិច្ចនោះ មិនបានចងដល់រដ្ឋ តាមរយៈខរក្សាសិទ្ធិនោះ។

**Further Readings:** 1. Kristina Ash, U.S. Reservations to the International Covenant on Civil and Political Rights: Credibility Maximization and Global Influence, 3 Nw. J. Int'l Hum. Rts. 1 (2005). http://scholarlycommons.law.northwestern.edu/njihr/vol3/iss1/7; International Law Commi ssion, Guide to Practice on Reservation to Treaties 2011, A/66/10, para.75; Elena A. Baylis, General Comment 24: Confronting the Problem of Reservations to Human Rights Treaties, 17 Berkeley J. Int'l Law. 277 (1999). UN Human Rights Committee (HRC), *CCPR General Comment No. 24: Issues Relating to Reservations Made upon Ratification or Accession to the Covenant or the Optional Protocols thereto, or in Relation to Declarations under Article 41 of the Covenant*, 4 November 1994, CCPR/C/21/Rev.1/Add.6, available at: https://www.refworld.org/docid/453883 fc11.html [accessed 24 August 2019]; United Nations, *Vienna Convention on the Law of Treaties*, 23 May 1969, United Nations, Treaty Series, vol. 1155, p. 331, available at: https://www.refworld.org/docid/3ae6b3a10.html [accessed 24 August 2019]